# រឿងទី៦៖ ម៉ូសេ៣ (សមុទ្រក្រហម)

**ខគម្ពីរ៖ និក្ខមនំ ១៤:១៣**

លោកម៉ូសេឆ្លើយទៅប្រជាជនវិញថា៖ «កុំភ័យខ្លាចអ្វីឡើយ! ចូរតាំងស្មារតីឡើង នៅថ្ងៃនេះ អ្នករាល់គ្នានឹងឃើញព្រះអម្ចាស់សង្គ្រោះអ្នករាល់គ្នា។ ជនជាតិអេស៊ីបដែលអ្នករាល់គ្នាឃើញនៅថ្ងៃនេះ អ្នករាល់គ្នានឹងលែងឃើញគេទៀតរហូតតទៅ។



ម៉ូសេបានចាប់ផ្ដើមធ្វើដំណើរដ៏សែនឆ្ងាយឆ្ពោះទៅទឹកដីស្រុកកាណានជាមួយប្រជារាស្ត្រអ៊ីស្រាអែល។
នៅពេលថ្ងៃ ព្រះជាម្ចាស់តែងយាងនាំមុខគេ បាំងពន្លឺព្រះអាទិត្យដោយបង្គោលពពកដ៏ធំ ពេលយប់ ទ្រង់យាងក្នុងបង្គោលភ្លើង ដើម្បីនឹងនាំផ្លូវពួកគេ។
ប្រជារាស្ត្រអ៊ីស្រាអែលបានធ្វើដំណើរទៅដល់សមុទ្រក្រហមដ៏ធំ។ ម៉ូសេ បានដំឡើងត្រសាលនៅទីនោះ ឱ្យមនុស្សទាំងអស់បានសម្រាក។
ចំណែកស្ដេចផារ៉ោនវិញ ក្រោយពីបានឱ្យប្រជារាស្ត្រអ៊ីស្រាអែលចេញទៅហើយ ទ្រង់មានការសោកស្ដាយជាខ្លាំង។
ដូច្នេះ ស្ដេចបានទឹមរាជរថ និងរទេះចំបាំងដែលមានពួកទ័ពយ៉ាងច្រើនឆ្ពោះតម្រង់ទៅវាលរហោស្ថាន។
ប្រជារាស្ត្រអ៊ីស្រាអែលដែលកំពុងអង្គុយសម្រាកនៅមាត់សមុទ្រ បានងើបភ្នែកឡើងឃើញពួកទាហានសាសន៍ អេស៊ីបកំពុងធ្វើដំណើរមកពីចម្ងាយ។
ពេលឃើញពួកទាហានសាសន៍អេស៊ីបមានគ្នាច្រើនដូច្នេះ ពួកគេមានការតក់ស្លុត ខឹងនឹងម៉ូសេជាខ្លាំង។
ម៉ូសេបាននិយាយទៅប្រជារាស្ត្រអ៊ីស្រាអែលថា៖ «ចូកុំខ្លាចអី ដ្បិតព្រះជាម្ចាស់ទ្រង់នឹងជួយសង្គ្រោះយើងជាមិនខាន»។
ពេលនោះ ពួកទាហានរបស់អេស៊ីប ក៏កាន់តែចូលមកជិតដល់ពួកគេ។
ព្រះជាម្ចាស់មានបន្ទូលទៅម៉ូសេថា៖ «ម៉ូសេអើយ ចូរអ្នកដឹកនាំរាស្ត្ររបស់យើង ឆ្លងកាត់សមុទ្រក្រហមទៅ! ចូរលើកដំបងរបស់អ្នកឡើងដាក់លើសមុទ្រ នោះសមុទ្រនឹងញែកចេញពីគ្នា ហើយឱ្យរាស្ត្រអ៊ីស្រាអែលទាំងអស់ដើរឆ្លងកាត់តាមដីស្ងួតនៅកណ្ដាល សមុទ្រនោះចុះ»។
ម៉ូសេបានធ្វើតាមព្រះបន្ទូលព្រះជាម្ចាស់ យកដំបងដាក់លើទឹកសមុទ្រដោយដៃទាំងពីរ។
ភ្លាមនោះ ស្រាប់តែមានខ្យល់មិនដឹងមកពីណាបក់មកយ៉ាងខ្លាំង។ ហើយទឹកសមុទ្រក៏ញែកជាពីរបញ្ឈរឡើងលើក្លាយជាជញ្ជាំង បង្កើតបានជាផ្លូវឱ្យមនុស្សម្នាអាចដើរឆ្លងកាត់បាន។
ប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់ក៏ដើរឆ្លងកាត់ដោយសុវត្ថិភាព។ ពេលនោះ ពួកទាហានរបស់អេស៊ីបក៏ដេញតាមមកពីក្រោយ ឆ្លងទៅតាម។
ពេលនោះ ម៉ូសេបានដាក់ដៃលើសមុទ្រម្ដងទៀត។ ភ្លាមនោះ ទឹកសមុទ្រក៏ផ្គុំចូលគ្នាវិញ ។
ពួកទាហានអេស៊ីបទាំងអស់ ខំរត់គេចពីទឹកសមុទ្រដែរ ប៉ុន្តែព្រះជាម្ចាស់បានធ្វើឱ្យពួកគេលិចចូលទៅក្នុងសមុទ្រ ទាំងអស់។
ប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់បានអរព្រះគុណដល់ព្រះជាម្ចាស់។ ហើយបានជឿព្រះជាម្ចាស់ និងម៉ូសេជាបាវបម្រើទ្រង់។
ដូច្នេះ ម៉ូសេគឺជាមនុស្សដែលព្រះជាម្ចាស់បានប្រើដើម្បីដឹកនាំប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់ឱ្យត្រឡប់ចូលទៅទឹកដីកាណានជាទឹកដីដែលព្រះបានសន្យាជាមួយពួកគេនោះ។



**សកម្មភាពទី១** ចូរបិទក្រដាសពណ៌ទៅលើសមុទ្រក្រហម កាត់យករូបលោកម៉ូសេ និងប្រជាជន រួចបិទទៅលើដីគោក។
(សម្ភារៈ៖ ក្រដាសពណ៌, កន្ត្រៃ, កាវ)









- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (និក្ខមនំ ១៤៖១៣)

នៅថ្ងៃនេះ អ្នករាល់គ្នានឹងឃើញព្រះអម្ចាស់សង្គ្រោះអ្នករាល់គ្នា។

**សកម្មភាពទី២** សូមគិតអំពីខ្លឹមសារមេរៀនដែលរៀនបាននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

